## ១. សេចក្តីផ្តើម

១.១ ឯកសារនេះថែងពីគោលនយោបាយថ្មីមួយសំរាប់អភិវឌ្ឍ **កម្មវិធីសិក្សាអប់រំមូលដ្ឋាន** (ថ្នាក់ទី ១-៩) និង**កម្មវិធីសិក្សាមធ្យមសិក្សាទុតិយភូមិ** (ថ្នាក់ទី១០-១២ ) នៅប្រទេសកម្ពុជា ក្នុងបរិបទដែលមានក្នុង **ផែនការជាតិអប់រំសំរាប់ទាំងអស់គ្នា ២០០៣- ២០១៥**។

1.2 ឯកសារគោលនយោបាយនេះបរិយាយពីគោលបំនង និងរចនាសម្ព័ន្ធនៃកម្មវិធីសិក្សា រួមទាំងម៉ោងបង្រៀន។ ខ្លឹមសារលំអិតនៃកម្មវិធីសិក្សានឹងមានពណ៌នាក្នុងឯកសារថ្មី **កម្មវិធីសិក្សាជាតិ**។

១.៣ រចនាសម្ព័ន្ធនៃកម្មវិធីសិក្សាក្នុងឯកសារនេះមានបំនងធ្វើអោយសំរេចរាល់ចំនុចគន្លឹះជាអាទិភាពទាំងឡាយរបស់ **ក្រសួងអប់រំ យុវជន និង កីឡា** (អ.យ.ក ) ដែលបានកំនត់ក្នុង **ផែនការជាតិអប់រំសំរាប់ទាំងអស់គ្នា ២០០៣-២០១៥** ដូចជា :

- សមធម៌ក្នុងការទទួលការអប់រំនៅកំរិតអប់រំមូលដ្ឋាន
- ការផ្តល់ការអប់រំប្រកបដោយគុណភាពខ្ពស់នៅមធ្យមសិក្សាទុតិយភូមិ
- គោលនយោបាយហិរញ្ញវត្ថុជួយដល់សិស្សក្រីក្រ
- ការគ្រប់គ្រងធនធានប្រកបដោយប្រសិទ្ធភាព
- ការបង្កើនការទទួលខុសត្រូវក្នុងការអភិវឌ្ឍស្តង់ដា ។

១.៤ ឯកសារនេះពណ៌នាលំអិតពីគោលនយោបាយនៃការទទួលខុសត្រូវក្នុងការផ្តល់មូលនិធិលើកម្មវិធីសិក្សាដោយ**ក្រសួងអប់រំ យុវជន និង កីឡា** និង មជ្ឈដ្ឋានពាក់ព័ន្ធ ។